ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

## ជំនួបរវាង ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង លោកស្រី Wan Hea-Lee តំណាងការិយាល័យឧត្តមស្នងការ សិទ្ធិមនុស្ស អ. ស. ប ប្រចាំកម្ពុជា

******

នៅព្រឹកថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង១០:០០ នៅទីស្តីការក្រសួង ឯកឧត្តម **ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យលោកស្រី Wan Hea-Lee តំណាងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប ប្រចាំកម្ពុជា (OHCHR) ចូលជួបពិភាក្សាការងារ។

នៅក្នុងជំនួប **ឯកឧត្តមទេសរដ្ឋមន្ត្រី**បានគូសបញ្ជាក់ថា នេះគឺជាការជួបពិភាក្សាការងារលើកទីមួយរវាង**ឯកឧត្តម** ជាមួយលោកស្រី Wan Hea-Lee បន្ទាប់ពីមានការចុះហត្ថលេខា នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ លើអនុស្សារណៈ (MOU) រវាងរាជរដ្ឋាភិបាលកម្ពុជា និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សម្រាប់ការអនុវត្តកម្មវិធីសហប្រតិបត្តិការបច្ចេកទេសស្តីពីសិទ្ធិមនុស្ស (For the Implementation of a Technical Cooperation Programme on Human Rights) សម្រាប់រយៈពេល២ឆ្នាំ ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨។ **ឯកឧត្តម** ក៏បានគូសបញ្ជាក់ពីគោលដៅនៃការពិភាក្សានេះគឺផ្តោតទៅលើបែបបទ និងរបៀបធ្វើការទៅថ្ងៃមុខរបស់ការិយាល័យ ដើម្បីអនុវត្តដោយជោគជ័យនូវ MOU ដែលបានចុះហត្ថលេខាកន្លងមកថ្មីៗនេះ។

លោកស្រី Wan Hea-Lee បានគូសបញ្ជាក់ជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីបំណងរបស់ការិយាល័យក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការពង្រឹងទំនាក់ទំនងការងារជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា។ លោកស្រីក៏បានគូសបញ្ជាក់ថា ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សបានចាត់ទុកថា ឆ្នាំថ្មីនេះគឺជាការចាប់ផ្តើមនៃដំណាក់កាលថ្មីមួយ នៃការពង្រឹងឡើងវិញនូវកិច្ចសហប្រតិបត្តិការ និងជំនឿទុកចិត្តរវាងការិយាល័យជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងន័យនេះ លោកស្រីបានគូសបញ្ជាក់ពីបំណងរបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ក្នុងការរៀបចំអោយមានការជួបពិគ្រោះគ្នាជាប្រក្រតី រវាងការិយាល័យជាមួយនិងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក៏ដូចជាការពង្រឹងទំនាក់ទំនងការងាររបស់ការិយាល័យជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជំរាបជូនលោកស្រី Wan Hea-Lee អំពីជំហរជាគោលការណ៍របស់ក្រសួងការបទេសនិងសហប្រតិបត្តិការអន្តរជាតិ នៅក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ ក៏ដូចជាក្នុងការកសាងនូវការជឿទុកចិត្តគ្នាទៅវិញទៅមក។ **ឯកឧត្តម** បានលើកឡើងអំពីការឯកភាពរបស់

ឯកឧត្តមចំពោះបំណងរបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ក្នុងការរៀបចំអោយមានការជួបពិគ្រោះគ្នាទៀងទាត់ រវាងការិយាល័យ ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយ**ឯកឧត្តម**បានផ្តល់អនុសាសន៍ឲ្យភាគីទាំងពីរខិតខំឲ្យមានជំនួបពិគ្រោះជាទៀងទាត់ លើមូលដ្ឋានរយៈពេលបីខែម្តង ទៅតាមភាពចាំបាច់នៃការងារ។ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានគូសបញ្ជាក់ថាការជួបពិគ្រោះនេះ និងការធ្វើអោយបានប្រសើរជាងមុននូវទំនាក់ទំនងរវាងភាគីទាំងពីរ គឺជាមូលដ្ឋានសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងពេលអនាគត។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ថា ការជួបពិគ្រោះគ្នារវាងភាគីទាំងពីរ នឹងចាប់ផ្តើមដោយកិច្ចប្រជុំមួយនាពេលឆាប់ៗនេះ រវាងរាជរដ្ឋាភិបាលកម្ពុជា និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ដែលក្នុងឱកាសនោះ ការិយាល័យនឹងជំរាបជូនរាជរដ្ឋាភិបាលកម្ពុជាពីគំរោងការងាររបស់ខ្លួនក្នុងឆ្នាំ២០១៧ ដែលនោះគឺជាផែនការសកម្មភាពរបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ដើម្បីជាគុណប្រយោជន៍ដល់ការលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងកសាងការជឿទុកចិត្តរវាងភាគីទាំងពីរ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានរំលឹកដល់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សឲ្យយកចិត្តទុកដាក់គោរពអធិបតេយ្យភាពរបស់កម្ពុជា ហើយជៀសវាងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ស្របតាមការកំណត់នៅក្នុងមាត្រា២(៧) នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងបទដ្ឋាននៃការប្រតិបត្តិសម្រាប់រដ្ឋការអន្តរជាតិ (Standards of Conduct for International Civil Service) ដែលបានកំណត់យ៉ាងច្បាស់ថា "មន្ត្រីរដ្ឋការ (civil servants) អន្តរជាតិទាំងអស់ មានកាតព្វកិច្ចត្រូវរក្សាទំនាក់ទំនងដ៏ល្អបំផុត ជាមួយរដ្ឋាភិបាល ហើយត្រូវជៀសវាងសកម្មភាពណាមួយដែលអាចប៉ះពាល់ដល់ទំនាក់ទំនងនេះ។ មន្ត្រីរដ្ឋការអន្តរជាតិ មិនត្រូវជ្រៀតជ្រែកចូលនយោបាយ ឬកិច្ចការរបស់រដ្ឋាភិបាលឡើយ។ ការទិះតៀន ឬការប៉ុនប៉ងបង្ខូចកេរ្តិ៍ឈ្មោះរបស់រដ្ឋាភិបាលពីសំណាក់មន្ត្រីរដ្ឋការអន្តរជាតិ ទោះបីមានលក្ខណៈជាបុគ្គល ឬជាក្រុមក៏ដោយ វាជាប្រការដែលមិនអាចទទួលយកបានឡើយ។"

នៅក្នុងក្របខ័ណ្ឌនៃការពង្រឹងកិច្ចសហប្រតិបត្តិការនេះដែរ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានលើកឡើងពីភាពចាំបាច់ក្នុងការថ្លឹងថ្លែង ចំពោះករណីដែលមានការប៉ះទង្គិចគ្នារវាងសិទ្ធិនានា (Clashes of Rights) ពោលគឺនៅពេលដែលការអនុវត្តនូវសិទ្ធិមួយមានការបំពានទៅលើសិទ្ធិមួយទៀត ក៏ដូចជាការប៉ះទង្គិចរវាងការងាររបស់ភ្នាក់ងារអន្តរជាតិជាមួយនឹងការប្រតិបត្តិច្បាប់ជាតិរបស់ប្រទេសម្ចាស់ផ្ទះ។

នៅក្នុងជំនួបនេះដែរ លោកស្រី Wan Hea-Lee បានអះអាងជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីភាពស្មោះត្រង់របស់លោកស្រីក្នុងការអនុវត្តភារកិច្ច ក្នុងក្របខ័ណ្ឌសិទ្ធិមនុស្សតែប៉ុណ្ណោះ។

នៅចុងបញ្ចប់នៃជំនួបពិភាក្សា **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីកត្តាចាំបាច់ជានាការអនុវត្តអោយបានជោគជ័យនូវអនុស្សារណៈ(MOU) រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ព្រមទាំងការពង្រឹងកិច្ចសហប្រតិបត្តិការ និងការកសាងជំនឿទុកចិត្តរវាងភាគីទាំងពីរ គឺចាំបាច់ត្រូវមានភាពស្មោះត្រង់ក្នុងការវិន្និច្ឆ័យ ឬការអនុវត្តភារកិច្ចសិទ្ធិមនុស្សរបស់ការិយាល័យ ការគោរពអធិបតេយ្យភាព មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា ហើយនិងដោះស្រាយការយល់ខុសគ្នាដោយការពិគ្រោះពិភាក្សា។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងយល់គ្នាទៅវិញទៅមក។

ភ្នំពេញ ថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ២០១៧